N.19
23.5.02

# ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៥-៣-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៣០២/០៧០តែងតាំង ឯកឧត្តម **ខូវ ផល្លាបុត្រ** ជាទីប្រឹក្សាផ្ទាល់របស់អគ្គលេខាធិការព្រឹទ្ធសភា ១២១៨

១៦-៥-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០៥០២/១២៣ ប្រោសព្រះរាជទានចំពោះឧកញ៉ា **គង់ ទ្រីវ** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **មហាសេរីវឌ្ឍន៍** ១២១៩

១៦-៥-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០៥០២/១២៤ ប្រោសព្រះរាជទានចំពោះឧកញ៉ា **ឡាវ ម៉េងឃីន** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **មហាសេរីវឌ្ឍន៍** ១២២០

១៦-៥-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០៥០២/១២៥ ប្រោសព្រះរាជទានចំពោះឧកញ៉ា **តូនី តង់ឌីហ្សូណ** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **មហាសេរីវឌ្ឍន៍** ១២២១

១៦-៥-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០៥០២/១២៦ ប្រោសព្រះរាជទានចំពោះលោក **ពុង ឃាវសែ** នូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **មហាសេរីវឌ្ឍន៍** ១២២២

១៦-៥-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០៥០២/១២៧ តែងតាំងលោក **ចាន់ ហ៊ិត** ជា **ឧកញ៉ា** ១២២៣

១៦-៥-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០៥០២/១២៨ តែងតាំងលោក **ម៉ែន ស៊ីផាន់** ជា **ឧកញ៉ា** ១២២៤

១៧-៥-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០៥០២/១៣០ តម្លើងឋានន្តរសក្តិជូននាយនគរបាលជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ១២២៥


## II– រាជរដ្ឋាភិបាល

### ១_ អនុក្រឹត្យ


១៧-៥-២០០២ - អនុក្រឹត្យលេខ ៤២ អនក្រ .បក ស្តីពីរបៀបរបបនិងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម ១២២៧

# ខ


២០-៥-២០០២ - អនុក្រឹត្យលេខ ៤៣ អនក្រ .បក ស្តីពីការផ្ទេរឥណទានថវិកា ១២៣៤

១៦-៥-២០០២ - អនុក្រឹត្យលេខ ២៣២ អនក្រ .តត ស្តីពីការផ្ទេរភារកិច្ចនិងតែងតាំងនាយនគរបាលជាតិជាន់ខ្ពស់ ១២៣៦

១៧-៥-២០០២ - អនុក្រឹត្យលេខ ២៣៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១២៣៨

១៧-៥-២០០២ - អនុក្រឹត្យលេខ ២៣៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៣៩

១៧-៥-២០០២ -អនុក្រឹត្យលេខ២៣៥អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយ នគរបាលជាតិ ១២៤០

១៧-៥-២០០២ -អនុក្រឹត្យលេខ២៣៦ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ១២៤១

២០-៥-២០០២ - អនុក្រឹត្យលេខ ២៣៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៤២

២០-៥-២០០២ - អនុក្រឹត្យលេខ ២៣៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៤៣

២០-៥-២០០២ - អនុក្រឹត្យលេខ ២៣៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៤៤

២០-៥-២០០២ - អនុក្រឹត្យលេខ ២៤០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១២៤៥

២១-៥-២០០២ - អនុក្រឹត្យលេខ ២៤១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១២៤៧

២១-៥-២០០២ - អនុក្រឹត្យលេខ ២៤២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១២៦៧

២១-៥-២០០២ - អនុក្រឹត្យលេខ ២៤៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៦៩

២១-៥-២០០២ - អនុក្រឹត្យលេខ ២៤៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១២៧០

២១-៥-២០០២ - អនុក្រឹត្យលេខ ២៤៥ អនក្រ.តត ស្តីពីការតែងតាំងសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិតសភាកម្ពុជា ១២៧៩

២១-៥-២០០២ - អនុក្រឹត្យលេខ ២៤៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៨១

២១-៥-២០០២ -អនុក្រឹត្យលេខ២៤៧ អនក្រ.តត ស្តីពីការតែងតាំងផ្លាស់ប្តូរមុខងារនាយ ទាហាន ១២៨២

២២-៥-២០០២ - អនុក្រឹត្យលេខ ២៤៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៨៣

២២-៥-២០០២ - អនុក្រឹត្យលេខ ២៤៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៨៤

២២-៥-២០០២ - អនុក្រឹត្យលេខ ២៥០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១២៨៥

២២-៥-២០០២ - អនុក្រឹត្យលេខ ២៥១អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៩១

២៣-៥-២០០២ -អនុក្រឹត្យលេខ ២៥២អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១២៩២


## សេចក្តីសំរេច


១៦-៥-២០០២ -សេចក្តីសំរេចលេខ ២៩ សសរ ស្តីពីការបង្កើតក្រុមការងារដើម្បីរៀបចំឯកសារគតិយុត្តិនិងពិនិត្យដោះស្រាយចំពោះគំរោងជួលនិងអភិវឌ្ឍន៍ កោះរុង និង កោះរុងសន្លឹម របស់ក្រុមហ៊ុន ISLAND DEVELOPMENT INC ១២៩៣

១៧-៥-២០០២ -សេចក្តីសម្រេចលេខ ៣០ សសរ ស្តីពីការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គ អាស៊ាន (AMBDC) លើកទី៤ ១២៩៦

## III-ការងារបណ្តាក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១៧-៥-២០០២ - ប្រកាសលេខ ៣៦២ សហវ .ប្រក ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាករាជធានីភ្នំពេញ ១២៩៩

១៧-៥-២០០២ - ប្រកាសលេខ ៣៦៤ សហវ.ប្រក ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការនូវទីស្នាក់ការគយ និងរដ្ឋាករមួយចំនួនតាមបណ្តា ខ័ណ្ឌនានានៃរាជធានីភ្នំពេញ ១៣០១

២២-៥-២០០២ - ប្រកាសលេខ ៣៧២ សហវ .វស ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីចុះពិនិត្យវាយតម្លៃលើផលប៉ះពាល់ដល់ប្រជារាស្ត្រ ពីគំរោងសាងសង់កំណាត់ផ្លូវ ជាតិលេខ២ ពីទីរួមខេត្តតាកែវ(អូរចំបក់) ទៅព្រំប្រទល់កម្ពុជាវៀតណាម (ភ្នំដិន) ១៣០៣

២០-៥-២០០២ - សេចក្តីសម្រេចលេខ០០២ សសរ.សហវ.ពដ ស្តីពីការកែប្រែសមាសភាពអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅខេត្តរតនគិរី ១៣០៥

### ២.ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២០-៥-២០០២ - ប្រកាសលេខ ១៤០ Moc/M2002 ស្តីពីការបង្កើតអនុគណៈកម្មការរៀបចំប្រជុំរដ្ឋមន្ត្រីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ាន(AMBDC) លើកទី៤ ១៣០៨

២៣-៥-២០០២ -ប្រកាសលេខ ១៤២ Moc/M2002 ស្តីពីការដាក់ឱ្យដេញថ្លៃលើកូតា សំលៀកបំពាក់ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិកសំរាប់ប្រើប្រាស់ក្នុងឆ្នាំ ២០០២ ១៣១៣

### ៣.ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

១៧-៥-២០០២ - ប្រកាសលេខ ៣៦០ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សាមង្គលមានលក្ខណ៍ ១៣១៧

# ឃ

## ៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ

### សារាចរ


| | | |
|---|---|---|
| ២២-៥-២០០២ | -សារាចរលេខ ១៥៧ សរ.កសក ស្តីពីវិធានការគ្រប់គ្រងនិងទប់ស្កាត់ភាពអនាធិបតេយ្យចលនាសត្វនិងផលិតផលមានដើមកំណើតពីសត្វ | ១៣១៨ |

# ព្រះរាជក្រឹត្យ

នស/រកត/០៣០២/០៩៧០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ខូច ផល្លាបុត្រ** ជាទីប្រឹក្សាផ្ទាល់របស់អគ្គលេខាធិការព្រឹទ្ធសភា ទទួលបន្ទុកកិច្ចការបរទេស និងវិនិយោគ មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២ :** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២

៣.រ.ល.០៣.០២.០០៧០

លេខៈ ១១៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១២៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម គង់ វិបុល

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

៣ាល.០២.០៥.០០១៣៣

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០០២

លេខៈ ១១៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី២០ ខែ ឧសភា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១៧៤

យើង

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

ឧកញ៉ា **ឡាវ ម៉េងឃីន**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

៣រល.០២.០៥.០០១៣៤

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០០២*

លេខ: ១១៧៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណារិទ្ធ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១២៥

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

ឧកញ៉ា គួនី តង់ឌីហ្សូណា

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រស-០២.០៥.០០១៣៥

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០០២*

លេខៈ ១១៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង ឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១២៦

យើង

ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

លោក **ពុង ឃាវសែ**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រល-០៥.០៥.០០១៣៦

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០០២*

លេខៈ ១១៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណារី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១២៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក ចាន់ ហ៊ិត

ជា

ឧកញ៉ា

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ: ១១៧ច.ល

ដើម្បីចម្លងចែក

៣៧៧-០២.០៥.០០១៣៧

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ ឧសភា ឆ្នាំ២០០២

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១២៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក ម៉ែន ស៊ីផាន់

ជា

ឧកញ៉ា

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

៣៤ស.០២.០៥.០០១៣៨

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២

លេខ: ១១៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០០២
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១៣០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២

## ត្រាស់បង្គាប់

**មាត្រា១** .- ត្រូវបានតម្លើងឋានន្តរស័ក្តិ ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

**ក-ថ្នាក់ឧត្តមសេនីយ៍ទោ :**

លោកឧត្តមសេនីយ៍ត្រី **ហេង ហាក់** អត្តលេខ ០០៦៣ អគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល ។

ខ- ថ្នាក់ឧត្តមសេនីយ៍ត្រី :

១-លោកវរសេនីយ៍ឯក សេង សារុណ អត្តលេខ ០២១៤ ប្រធានអធិការដ្ឋានកិច្ចការនគរបាល នៃអគ្គាធិការដ្ឋាន កិច្ចការនយោបាយ រដ្ឋបាល និង នគរបាល ។

២-លោកវរសេនីយ៍ឯក ត្រី ឌុច អត្តលេខ ០១៦៦ អនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយ នឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខៈ ១១៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ាន់ សាន់

ថ.ល.-០២.០៥.-០០១៤០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## របៀបរបប និង ការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើ ច្បាប់ ស្តីពីសភាពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សំរេច

## ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១ :**

សភាពាណិជ្ជកម្ម មានសមាជិកជ្រើសតាំងតាមការបោះឆ្នោត និង សមាជិកកិត្តិយស ។

សមាជិកជ្រើសតាំងតាមការបោះឆ្នោត ត្រូវបានកំណត់ដោយអនុក្រឹត្យបង្កើតសភាពាណិជ្ជកម្មនីមួយៗ ហើយចំនួនសមាជិកទីប្រឹក្សា ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

អាណត្តិរបស់សមាជិកសភាពាណិជ្ជកម្មមានរយៈពេល ០៦ ឆ្នាំ ។ រៀងរាល់ ០៣ឆ្នាំម្តង សភាពាណិជ្ជកម្មត្រូវរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងថ្មីចំនួនពាក់កណ្តាល លើកលែងតែនៅក្នុងអាណត្តិដំបូង ត្រូវមានការចាប់ឆ្នោតជ្រើសរើសសមាជិកចំនួនពាក់កណ្តាល ដែលត្រូវបញ្ចប់អាណត្តិ ក្រោយរយៈពេល ០៣ ឆ្នាំ ។

**<u>មាត្រា ២</u> :**

សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្ម ត្រូវចូលបំពេញការងាររបស់ខ្លួនក្រោយថ្ងៃប្រកាសលទ្ធផលបោះឆ្នោតយ៉ាងយូរមួយខែ ក្រោមអធិបតីភាពរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬតំណាង និង អភិបាលខេត្ត-ក្រុង ឬតំណាងនៃមណ្ឌលរបស់សាមីសភាពាណិជ្ជកម្ម ។

**<u>មាត្រា ៣</u> :**

ក្នុងករណីដែលចំនួនសមាជិកជ្រើសតាំងធ្លាក់មកនៅទាបជាងពាក់កណ្តាល សភាពាណិជ្ជកម្មត្រូវបានរំសាយ ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។ ការជ្រើសតាំងសមាជិកជាថ្មីត្រូវធ្វើក្នុងរយៈពេល ០៣ខែយ៉ាងយូរ គិតពីថ្ងៃចេញអនុក្រឹត្យ ។

ក្រសួងពាណិជ្ជកម្មត្រូវប្រកាសតែងតាំងគណៈកម្មការបណ្តោះអាសន្នមួយ ដើម្បីដឹកនាំសភាពាណិជ្ជកម្មជាបន្ទាន់ ។

# ជំពូកទី ២

## គណៈកម្មការរៀបចំការបោះឆ្នោត

**<u>មាត្រា ៤</u> :**

ក/- គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម អាណត្តិទី ១ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - តំណាងក្រសួងពាណិជ្ជកម្ម | ប្រធាន |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់ | អនុប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | |
| - តំណាងក្រសួងមហាផ្ទៃ | |
| - តំណាងសាលាខេត្ត-ក្រុង សាមី | |

- តំណាងក្រសួងទេសចរណ៍ សមាជិក
- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
- តំណាងធនាគារជាតិនៃកម្ពុជា សមាជិក
- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- តំណាងក្រសួងយុត្តិធម៌ សមាជិក
- មន្ត្រីក្រសួងពាណិជ្ជកម្ម ០២រូប លេខាធិការ

ខ/-គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម អាណត្តិបន្តបន្ទាប់ មានសមាសភាពដូចខាងក្រោម :

- តំណាងក្រសួងពាណិជ្ជកម្ម ប្រធាន
- តំណាងសាមីសភាពាណិជ្ជកម្ម អនុប្រធាន
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងសាលា ខេត្ត-ក្រុង សាមី សមាជិក
- អគ្គនាយកសាមីសភាពាណិជ្ជកម្ម លេខាធិការ

**មាត្រា ៥ :**

គណៈកម្មការរៀបចំការបោះឆ្នោត មានភារកិច្ចដូចតទៅ :

- ណែនាំលំអិត ស្ដីពីបែបបទបោះឆ្នោត ដល់សាធារណជន
- ធ្វើបញ្ជីអ្នកមានសិទ្ធិបោះឆ្នោតតាមប្រភេទអាជីវកម្មនីមួយៗ ប្រភេទពាណិជ្ជកម្ម ប្រភេទឧស្សាហកម្ម និងសិប្បកម្ម ប្រភេទសេវាកម្មនិងវិជ្ជាជីវៈសេរី ប្រភេទកសិកម្ម ។ បញ្ជីនេះត្រូវចុះហត្ថលេខាបញ្ជាក់ដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។
- ធ្វើប័ណ្ណគ្រប់ជំពូកសំរាប់ការបោះឆ្នោត
- ធ្វើបញ្ជីបេក្ខជនឈរឈ្មោះ ជាសមាជិកជ្រើសតាំងរបស់សភាពាណិជ្ជកម្ម ។ បញ្ជីនេះត្រូវចុះហត្ថលេខាបញ្ជាក់ដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។
- ចាត់រាល់វិធានការណ៍សំរាប់ត្រួតពិនិត្យមើលការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- រៀបចំការិយាល័យបោះឆ្នោត ។

- ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធិភាព គណៈកម្មការរៀបចំការបោះឆ្នោត មានសិទ្ធិលប់ឈ្មោះបេក្ខជនណាមួយ ចេញពីបញ្ជីបេក្ខជន ក្នុងករណីដែលសាមីខ្លួនមិនគោរពបែបបទ និងការណែនាំរបស់គណៈកម្មការក្នុងការបោះឆ្នោត ។

## មាត្រា ៦ :

ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការកំណត់ទីតាំងរបស់គណៈកម្មការសំរាប់ការបោះឆ្នោតនៅអាណត្តិទី ១ ។ ចំពោះការបោះឆ្នោតសំរាប់អាណត្តិបន្តបន្ទាប់ទៀត ទីតាំងសំរាប់គណៈកម្មការនេះត្រូវកំណត់ដោយសាមីសភាពាណិជ្ជកម្ម ។

សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំ និងបំពេញការងារតាមការកំណត់របស់ប្រធាន ។

សេចក្តីសំរេចរបស់គណៈកម្មការ នឹងមានសុពលភាពបាន លុះណាតែមានសមាជិកចំនួនពាក់-កណ្តាលយ៉ាងតិចមកចូលរួមប្រជុំ ។

## មាត្រា ៧ :

រាល់ការចំណាយរបស់គណៈកម្មការក្នុងការរៀបចំបោះឆ្នោតនៅអាណត្តិទី ១នេះ ជាបន្ទុករបស់ថវិការដ្ឋ ។ ការចំណាយសំរាប់ការបោះឆ្នោតនៅអាណត្តិបន្តបន្ទាប់ទៀត ជាបន្ទុករបស់សាមីសភាពាណិជ្ជកម្ម ។

# ជំពូកទី ៣

## ការបោះឆ្នោត

## មាត្រា ៨ :

ក/- អ្នកមានសិទ្ធបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មអាណត្តិទី ១ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

១- មានសញ្ជាតិជាខ្មែរ

២- មានអាយុយ៉ាងតិច ១៨ ឆ្នាំ

៣- ជាពាណិជ្ជករ ឧស្សាហករ សិប្បករ អ្នកធ្វើសេវាកម្មទេសចរណ៍ អ្នកធ្វើអាជីវកម្មកសិកម្ម អ្នកធ្វើសេវាកម្មផ្សេងៗទៀត សហគ្រាស និងក្រុមហ៊ុននានាដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ឬបានទទួលការអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ចណាមួយឱ្យធ្វើអាជីវកម្ម ហើយដែលមានទីស្នាក់ការ ឬអាគារធ្វើអាជីវកម្មនៅតាមខេត្ត-ក្រុង សាមី ។

ខ/- អ្នកមានសិទ្ធិបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មអាណត្តិបន្តបន្ទាប់ទៀត ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

៤- មានសញ្ជាតិជាខ្មែរ

៥- មានអាយុយ៉ាងតិច ១៨ ឆ្នាំ

៦- ជាសមាជិករបស់សាមីសភាពាណិជ្ជកម្ម

**មាត្រា ៩ :**

អ្នកមានសិទ្ធិបោះឆ្នោត ត្រូវសុំចុះឈ្មោះបោះឆ្នោត នៅក្នុងបញ្ជីអ្នកបោះឆ្នោតរបស់គណៈកម្មការរៀបចំការបោះឆ្នោត តាមការកំណត់របស់គណៈកម្មការនេះ ។

នៅក្រោយពេលបញ្ចប់ការចុះឈ្មោះ បញ្ជីអ្នកបោះឆ្នោតត្រូវបិទផ្សាយនៅក្រសួងពាណិជ្ជកម្ម និងនៅសាលាខេត្ត-ក្រុង ។

ក្នុងករណីមានការតវ៉ា រាល់អ្នកមានសិទ្ធិបោះឆ្នោតអាចប្តឹងតវ៉ាមកគណៈកម្មការ ក្នុងរយៈពេល ១៥ថ្ងៃយ៉ាងយូរ គិតពីថ្ងៃដែលបានបិទផ្សាយបញ្ជី ។

ហួសពីរយៈពេលនេះ គណៈកម្មការបោះឆ្នោតបញ្ចប់បញ្ជីជាស្ថាពរ ។ រាល់ការតវ៉ាត្រូវឈប់ទទួល ។

**មាត្រា ១០ :**

ក/- បេក្ខជនសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មអាណត្តិទី ១ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

១- បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ

២- មានអាយុយ៉ាងតិច ៣០ឆ្នាំ

៣- បានបង់ថ្លៃសិទ្ធិឈរឈ្មោះបោះឆ្នោតតាមការកំណត់របស់គណៈកម្មការបោះឆ្នោត

៤- មិនបានប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ ។

ខ/- បេក្ខជនសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មអាណត្តិបន្តបន្ទាប់ទៀត ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

១- បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ

២- ជាសមាជិករបស់សាមីសភាពាណិជ្ជកម្ម និងជាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម និងបានបំពេញកាតព្វកិច្ចបង់ពន្ធជូនរដ្ឋត្រឹមត្រូវនៅឆ្នាំអាជីវកម្មកន្លងមក

៣- មានអាយុយ៉ាងតិច ៣០ ឆ្នាំ

៤- បានបង់ថ្លៃសិទ្ធិឈរឈ្មោះបោះឆ្នោត តាមការកំណត់របស់គណៈកម្មការបោះឆ្នោត

៥- មិនបានប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ ។

## មាត្រា ១១ :

បេក្ខជនដែលចង់ឈរឈ្មោះជាសមាជិកជ្រើសតាំង ត្រូវសុំចុះឈ្មោះជាបេក្ខជនក្នុងបញ្ជីបេក្ខជនរបស់គណៈកម្មការរៀបចំការបោះឆ្នោត តាមការកំណត់របស់គណៈកម្មការនេះ ។ ការសុំចុះឈ្មោះនេះត្រូវធ្វើដោយសាមីបេក្ខជនផ្ទាល់ និង ចុះហត្ថលេខាដោយផ្ទាល់ដៃលើសំណុំបែបបទផ្សេងៗ ។

បញ្ជីបណ្តោះអាសន្ននៃបេក្ខជន ត្រូវបញ្ឈប់ ១៥ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ បញ្ជីនេះត្រូវបិទផ្សាយនៅក្រសួងពាណិជ្ជកម្ម និង នៅសាលាខេត្ត-ក្រុង ។

យ៉ាងយូរ ០៧ថ្ងៃ មុនថ្ងៃបោះឆ្នោត បេក្ខជនមានសិទ្ធិតវ៉ាទៅរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អំពី ការរារាំងមិនអោយខ្លួនចុះឈ្មោះ ឬភ្លេចចុះឈ្មោះខ្លួននៅក្នុងបញ្ជីនេះ ។

បញ្ជីបេក្ខជនជាស្ថាពរត្រូវបញ្ចប់ ០៧ ថ្ងៃ មុនពេលបោះឆ្នោត ។ ចាប់ពីថ្ងៃបញ្ចប់តទៅមិនអនុញ្ញាតិឱ្យធ្វើការតវ៉ាទេ ។ បញ្ជីស្ថាពរនេះត្រូវបិទផ្សាយនៅទីកន្លែងដែលបានបិទផ្សាយបញ្ជីបណ្តោះអាសន្ន ។

## មាត្រា ១២ :

ការបោះឆ្នោតមានដំណើរប្រព្រឹត្តទៅដូចខាងក្រោម :

១- ការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងរបស់សភាពាណិជ្ជកម្ម ត្រូវបានអនុវត្តតាមគោលការណ៍ :

- យកសំលេងភាគច្រើន
- បោះឆ្នោតតាមឈ្មោះនីមួយៗ
- បោះឆ្នោតតែមួយជុំ

ក្នុងករណីដែលមានបេក្ខជនច្រើននាក់ទទួលសំលេងស្មើគ្នានោះ ត្រូវជ្រើសតាំងបេក្ខជនដែលមានអាយុច្រើនជាង ។

២- ការិយាល័យបោះឆ្នោតត្រូវបានរៀបចំតែមួយកន្លែង ហើយរយៈពេលបោះឆ្នោតត្រូវកំណត់តែមួយថ្ងៃ គឺចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ១៥:០០ ល្ងាច ។

៣- ការឃោសនាបោះឆ្នោតជាសាធារណៈ ត្រូវកំណត់ចាប់ផ្តើម ១៥ថ្ងៃ មុនថ្ងៃបោះឆ្នោតតាមប្រតិទិនរបស់គណៈកម្មការរៀបចំការបោះឆ្នោត ហើយត្រូវបញ្ចប់ ៣ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៤- អ្នកបោះឆ្នោត ត្រូវយកប័ណ្ណបោះឆ្នោតមកជាមួយសំរាប់ដូរយកសន្លឹកឆ្នោត ។ អ្នកបោះឆ្នោតត្រូវមកបោះឆ្នោតដោយផ្ទាល់ ។ ប្រសិនបើមានការបាត់បង់ប័ណ្ណបោះឆ្នោត អ្នកបោះឆ្នោតត្រូវប្រកាសប្រាប់គណៈកម្មការរៀបចំការបោះឆ្នោតជាលាយលក្ខណ៍អក្សរ ១ថ្ងៃ មុនថ្ងៃបោះឆ្នោត ដើម្បីសុំប្តូរយកប័ណ្ណបោះឆ្នោតថ្មី ។

៥- បេក្ខជននីមួយៗមានសិទ្ធិចាត់តាំងតំណាងម្នាក់ អោយចូលសង្កេតការណ៍ក្នុងកិច្ចដំណើរការនៃការបោះឆ្នោតជាមួយគណៈកម្មការ ។

៦- គណៈកម្មការបោះឆ្នោត ត្រូវអញ្ជើញក្រសួង ស្ថាប័នពាក់ព័ន្ធ មួយចំនួនអោយចូលរួមធ្វើជាអ្នកសង្កេតការណ៍ ។

៧- ការរាប់សន្លឹកឆ្នោតត្រូវរាប់អោយចប់នៅថ្ងៃបោះឆ្នោត ហើយយោងតាមកំណត់ហេតុនៃគណៈកម្មការបោះឆ្នោត រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវប្រកាសលទ្ធផលនៃការបោះឆ្នោតនៅថ្ងៃដដែល។ លទ្ធផលនេះត្រូវចាត់ទុកជាស្ថាពរ ពុំអាចត្រូវបានតវ៉ានៅចំពោះមុខអង្គការណាបានឡើយ ។ ការទទួលស្គាល់សមាជិកជ្រើសតាំងរបស់សភាពាណិជ្ជកម្ម ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១៣ :**

អនុក្រឹត្យលេខ ៦៣អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម និងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៤ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ និងសភាពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៤៣...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១.៣៧៥ លានរៀល ( មួយពាន់បីរយចិតសិបប្រាំលានរៀល ) ពីជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) មកជំពូក ១០ ( បៀវត្ស និង ប្រាក់បំណាច់ ) របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បើកប្រាក់ឧត្ថម្ភជូនមន្ត្រីបច្ចេកទេស នៃមាត់ច្រកទូរគមនាគមន៍ អន្តរជាតិ ( ០០១ ) រយៈពេល ១១ ខែឆ្នាំ ២០០២ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ត្រូវ ទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៣៧២ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការផ្ទេរភារកិច្ច និងតែងតាំង
# នាយនគរបាលជាតិជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត / ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ-តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /ន/ស៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ /១៧៨ ចុះថ្ងៃទី២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន នៃក្រសួងមហាផ្ទៃ ។
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំកែសំរួលនាយក-ដ្ឋានមួយចំនួន នៃក្រសួងមហាផ្ទៃ ។
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## សំរេច

**មាត្រា១:** ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃដូចមានរាយនាមខាងក្រោម :

១- លោក ឧត្តមសេនីយ៍ត្រី **អ៊ុត គឹមលេខ** អត្តលេខ០០៣៨ បច្ចុប្បន្នប្រធាននាយក**ដ្ឋាននគរបាល** រដ្ឋបាល ជាប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និង អគ្គីភ័យនៃក្រសួងមហាផ្ទៃ ។

២- លោក ឧត្តមសេនីយ៍ត្រី **សួស អច្ចារី** អត្តលេខ ០១៣២ បច្ចុប្បន្នអនុប្រធាន**ទី១នាយកដ្ឋាន** នគរបាលរដ្ឋបាល ជាប្រធាននាយកដ្ឋាននគរបាលស្ថិតិ និង លិខិតឆ្លងដែន នៃក្រសួងមហាផ្ទៃ ។

៣- លោកស្រីឧត្តមសេនីយ៍ត្រី **អ៊ុន សុគន្ធា** អត្តលេខ ០២៥៩ ពីអនុប្រធាននាយក**ដ្ឋានផែនការ** សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទៅជាប្រធាននាយដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារ**អនីតិជននៃ** ក្រសួងមហាផ្ទៃ ។

៤- លោកវរសេនីយ៍ឯក **ខ៉ាន់ ណយ** អត្តលេខ ០២០៣ ពីអនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ ទៅជា ប្រធានការិយាល័យបុគ្គលិក ភស្តុភារ គណនេយ្យ នៃ ខុទ្ទកាល័យក្រសួងមហាផ្ទៃ ។

មាត្រា២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួ ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភា ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ ២០០

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៣៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់មេបញ្ជាការកងពលតូចលេខ ៧០

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូននាយទាហានចំនួន ០៦ រូប ដែលមានស្នាដៃល្អ ក្នុងការបំរើជាតិមាតុភូមិ ដូចមាននាមខាងក្រោម ÷

១-លោកវរសេនីយឯក **រ័ត្ន ស្រ៊ាង** មេបញ្ជាការកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ
២-លោកវរសេនីយត្រី **ហាក់ ម៉ៅ** នាយរងការិយាល័យទី២ កងពលតូចលេខ ៧០
៣-លោកវរសេនីយត្រី **ហែម ថេង**
៤-លោកអនុសេនីយឯក **សម្បត្តិ មុន្នីរ័ត្ន**
៥-លោកអនុសេនីយឯក **ស សេរីវិចិត្រ**
៦-លោកអនុសេនីយឯក **ហេង លី**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង មេបញ្ជាការកងពលតូចលេខ ៧០ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៧៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់មេបញ្ជាការកងពលតូចលេខ ៧០

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០២ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនជួយឧបត្ថម្ភដល់ការកសាង អង្គភាពកងពលតូចលេខ ៧០ ដូចមាននាមខាងក្រោម ÷

**ក.មេដាយមាសស្ថាបនាជាតិ**

-លោក **ចេន ជាជាង** នាយកក្រុមហ៊ុន ធី ស៊ី អឹម ថវិកាចំនួន ១០.០០០ USD

**ខ.មេដាយប្រាក់ស្ថាបនាជាតិ**

-លោក **មាស សម** នាយករងក្រុមហ៊ុន ធី ស៊ី អឹម ថវិកាចំនួន ៥.០០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង មេបញ្ជាការកងពលតូចលេខ ៧០ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៣៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជូននាយនគរបាលជាតិ នៃ ក្រសួងមហាផ្ទៃដូចមានរាយនាមខាងក្រោម:

១- លោកវរៈសេនីយ៍ទោ **វង្ស សោភ័ណ្ឌារ៉ា** អត្តលេខ ០៦៥៦ អនុប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ ។

២- លោកវរៈសេនីយ៍ទោ **ម៉ែន សុផុន** អត្តលេខ ០១៣៣៣ អនុប្រធាននាយកដ្ឋានសន្តិសុខសង្គម ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៣៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោកវរសេនីយ៍ទោ **គី ប៊ុនធឿន** អត្តលេខ ០៦២៧ អនុប្រធាននាយកដ្ឋាននគរបាល-ទេសចរណ៍ ។

២-លោកវរសេនីយ៍ទោ **រុំ តិត្ថមុន្នី** អត្តលេខ ០៩៦៦០ នាយនគរបាលជាតិជាន់ខ្ពស់ និងបច្ចុប្បន្ន ជាអភិបាលរងទី ២ ខេត្តកណ្តាល ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល :*
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ២*
*-ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ២៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តព្រៃវែង

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០២ រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ដើម្បីជួយកសាងសមិទ្ធផលនានា ស្ថិតនៅក្នុងស្រុកព្រៃវែង ខេត្តព្រៃវែង ដូចមាននាមខាងក្រោមនេះ ÷

១-លោកយាយ **ពត ឡាយ** នៅសហរដ្ឋអាមេរិក ថវិកា ៤០.២២០ USD

២-លោកប្រធានអង្គការ **ឆាំដឹក** ខេត្តព្រៃវែង ថវិកា ១២.៤៥០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ២៣៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ០៥ រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ដើម្បីជួយកសាងសមិទ្ធផលនានា ស្ថិតនៅក្នុងស្រុកស្វាយជ្រំ ស្រុកចន្ទ្រា និង ស្រុកស្វាយទាប ខេត្តស្វាយរៀង ដូចមាននាមខាងក្រោមនេះ ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

១-លោក **ញាណ ស្រស់** ថវិកា ១២.៨០០ USD
២-លោក **គុជ ស៊ីចាន់** និងអ្នកស្រី **សៅ ស៊ីណាន់** ថវិកា ១០.៣០០ USD
៣-លោក **គង់ សំ** ថវិកា ១០.២០០ USD

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-ឯកឧត្តមឧត្តមសេនីយ **ម៉ុល និត្យ** ថវិកា ៤.៧៤០ USD
២-ព្រឹទ្ធាចារ្យ **ហ៊ុន នាង** ថវិកា ១.០០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៣៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម GOTARO OGAWA ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់ថវិកាចំនួន ៩៣.០០០ ដុល្លារអាមេរិក ដើម្បីសាងសង់អគារសិក្សា ០១ ខ្នង ០២ ជាន់ មាន ១២ បន្ទប់ ធ្វើអំពីឥដ្ឋ ប្រក់ក្បឿង ស្ថិតនៅក្នុងវិទ្យាល័យវត្តកោះ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៧០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ។
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ។

## ស ំ រេ ច

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រីរាជការនៃក្រសួងសាធារណការនិងដឹកជញ្ជូន ដូចមានរាយនាមខាងក្រោម ÷

១- លោក យិត ប៊ុណ្ណា ជានាយកមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស

២- លោក ហ៊ា ស៊ីមសុរិយា ជានាយក នាយកដ្ឋានផែនការ

៣- លោក គីង ភារ៉ាទ្រី ជានាយក នាយកដ្ឋានផ្លូវទឹក

៤- លោក ដែន សុទិដ្ឋារនេះ ជានាយក នាយកដ្ឋានសំណង់ផ្លូវអាកាស

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០២

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៤១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

~~~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូនដល់នាយទាហាន នាយទាហានរងចំនួន ៥៣២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម ÷

**ក – មេដាយមាសការងារ ១០៣រូប**

១ - ឧត្តមសេនីយ៍ឯក ចៅ តិរុណា អត្តលេខ ០០០០៧៥ អគ្គនាយក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

២ - ឧត្តមសេនីយ៍ឯក ណាង ផាត អត្តលេខ ០០០០៨០ អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា

៣ - ឧត្តមសេនីយ៍ឯក តួច ស៊ីផាន អត្តលេខ ០០០០៥១ នាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន

៤ - ឧត្តមសេនីយ៍ឯក សឺង សំណាង អត្តលេខ ០០០១០១ មេបញ្ជាការ កងទ័ពជើងអាកាស

៥ - ឧត្តមនាវីឯក អ៊ុង សំខាន់ អត្តលេខ ០០០០៤២ មេបញ្ជាការ កងទ័ពជើងទឹក

៦ - ឧត្តមសេនីយ៍ទោ អ៊ូ គីមឡឿន អត្តលេខ ០០០៤៨១ អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ

៧ - ឧត្តមសេនីយ៍ទោ សំ ខណ្ឌឋន អត្តលេខ ០០០២០៥ នាយក ខុទ្ទកាល័យក្រសួងការពារជាតិ

៨ - ឧត្តមសេនីយ៍ទោ ម៉ីត សារុន អត្តលេខ ០០០០៩១ នាយក ទិចាត់ការចលនូបត្ថម្ភ

៩ - ឧត្តមសេនីយ៍ទោ អ៊ុង សារិន អត្តលេខ ០០០១១៣ នាយក វិទ្យាស្ថានយោធាកម្ពុជា

១០ - ឧត្តមសេនីយ៍ទោ ផាង គង់ អត្តលេខ ០០០១២០ មេបញ្ជាការ យោធភូមិភាគទី ១
~~~~~~~~

១១ - ឧត្តមសេនីយ៍ទោ កែច សាម្ងួន អត្តលេខ ០០០១២៩ មេបញ្ជាការ យោធភូមិភាគទី ៣

១២ - ឧត្តមសេនីយ៍ទោ ជា ម៉ន អត្តលេខ ០០០១៣៥ មេបញ្ជាការ យោធភូមិភាគទី ៤

១៣ - ឧត្តមសេនីយ៍ទោ ប៊ុន សេង អត្តលេខ ០០០១៤៥ មេបញ្ជាការ យោធភូមិភាគទី ៥

១៤ - ឧត្តមសេនីយ៍ទោ ព្រហ្ម ឌិន អត្តលេខ ០០០០៣៦ មេបញ្ជាការ យោធភូមិភាគពិសេស

១៥ - ឧត្តមសេនីយ៍ទោ យឹម សាឌី អត្តលេខ ០០០០៧៧ អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ និងជានាយក នាយកដ្ឋានប្រេងឥន្ធនៈ

១៦ - ឧត្តមសេនីយ៍ត្រី ប៉ុង ធារ៉ូ អត្តលេខ ០០០៥២៥ នាយករង ខុទ្ទកាល័យក្រសួងការពារជាតិ

១៧ - ឧត្តមសេនីយ៍ត្រី ផាន់ សាមន្តា អត្តលេខ ០០១១៨៨ នាយក នាយកដ្ឋានសោធននិវត្តន៍

១៨ - ឧត្តមសេនីយ៍ត្រី សួស សារ៉េន អត្តលេខ ០០០២២៨ នាយករង វិទ្យាស្ថានយោធាកម្ពុជា

១៩ - ឧត្តមសេនីយ៍ត្រី ពេជ្រ ស៊ាត អត្តលេខ ០០០៤៩៤ នាយករង វិទ្យាស្ថានយោធាកម្ពុជា និងជានាយកមជ្ឈមណ្ឌលហ្វឹកហ្វឺនយុទ្ធសាស្ត្រយោធា

២០ - ឧត្តមសេនីយ៍ត្រី ហាត់ សាធុច អត្តលេខ ០០០៥១១ នាយករង វិទ្យាស្ថានយោធាកម្ពុជា និងជានាយកមជ្ឈមណ្ឌលហ្វឹកហ្វឺនបញ្ជាការ សេនាធិការ

២១ - ឧត្តមសេនីយ៍ត្រី គង់ ប៊ុនថន អត្តលេខ ០០០១៣១ មេបញ្ជាការរង និងជានាយសេនាធិការយោធភូមិភាគទី ៣

២២ - ឧត្តមសេនីយ៍ត្រី ភឿក សាម៉ន អត្តលេខ ០០០២៥៣ នាយករង នាយកដ្ឋានសោធននិវត្តន៍

២៣ - ឧត្តមសេនីយ៍ត្រី ស៊ែស ខឡូសស្តា អត្តលេខ ០០០៤៦១ មេបញ្ជាការរង កងទ័ពជើងអាកាស

២៤ - ឧត្តមនាវីត្រី សៅ សារិន អត្តលេខ ០០០២៩៧ មេបញ្ជាការរង និងជានាយសេនាធិការកងទ័ពជើងទឹក

២៥ - ឧត្តមនាវីត្រី អ៊ុត ស៊ីហា អត្តលេខ ០០០៤៤០ មេបញ្ជាការ មូលដ្ឋានសមុទ្រ

២៦ - ឧត្តមសេនីយ៍ត្រី ពូ សាប៊ុនធី អត្តលេខ ០០០១០៩ មេបញ្ជាការរង និងជានាយសេនាធិការយោធភូមិភាគពិសេស

២៧ - ឧត្តមសេនីយ៍ត្រី ព្រហ្ម សារឿន អត្តលេខ ០០០១៣២ មេបញ្ជាការរង យោធភូមិភាគទី ៤

២៨ - ឧត្តមសេនីយ៍ត្រី កែច ធី អត្តលេខ ០០០១៣៧ មេបញ្ជាការរង និងជានាយសេនាធិការយោធភូមិភាគទី ៤

២៩ - ឧត្តមសេនីយ៍ត្រី អ៊ុយ សុភាព អត្តលេខ ០០០១៤០ មេបញ្ជាការ កងពលធំអន្តរាគមន៍លេខ ២

៣០ - ឧត្តមសេនីយ៍ត្រី ប៉ែន ឌ៉ុយ អត្តលេខ ០០៣៨១២ មេបញ្ជាការ កងពលតូចថ្មើរជើងលេខ ១៥

៣១ - ឧត្តមសេនីយ៍ត្រី ឯក សំអូន អត្តលេខ ០០០៦០៥ មេបញ្ជាការរង និងជានាយសេនាធិការយោធភូមិភាគទី ៥

៣២ - ឧត្តមសេនីយ៍ត្រី គួយ ដោត អត្តលេខ ០០០៤២១ មេបញ្ជាការរង យោធភូមិភាគទី ៥

៣៣ - ឧត្តមសេនីយ៍ត្រី ឈឿន សារិទ្ធ អត្តលេខ ០០០១៤៨ មេបញ្ជាការ កងពលតូចថ្មើរជើងលេខ ៦

៣៤ - ឧត្តមសេនីយ៍ត្រី សួរ ចាន់ហេង អត្តលេខ ០០០១៤៩ មេបញ្ជាការ កងពលតូចលេខ ៧

៣៥ - ឧត្តមសេនីយ៍ត្រី មាស សំអឿន អត្តលេខ ០០០៣៩៤ មេបញ្ជាការ កងពលតូចថ្មើរជើងលេខ ១២

៣៦ - ឧត្តមសេនីយ៍ត្រី នួយ ប៊ុនសី អត្តលេខ ០០០៣៩០ មេបញ្ជាការ កងពលតូចថ្មើរជើងលេខ ១៦

៣៧ - ឧត្តមសេនីយ៍ត្រី ញ៉ៀម គង់ អត្តលេខ ០០៤២៦៧ មេបញ្ជាការ កងពលតូចថ្មើរជើងលេខ ១៧

៣៨ - ឧត្តមសេនីយ៍ត្រី ជឹម តើយ អត្តលេខ ០០០៤០១ មេបញ្ជាការ កងពលតូចថ្មើរជើងលេខ ១៧

៣៩ - ឧត្តមសេនីយ៍ត្រី ស្រី សុបិន អត្តលេខ ០០៣៨១៦ មេបញ្ជាការ កងពលតូចថ្មើរជើងលេខ ១៩

| | | | | | |
|---|---|---|---|---|---|
| ៤០ - | ឧត្តមសេនីយ៍ត្រី | ជា | ត្លូចនិរម្យ | អត្តលេខ ០០៣៨១៧ | មេបញ្ជាការ កងពលតូចថ្មើរជើងលេខ ២០ |
| ៤១ - | ឧត្តមសេនីយ៍ត្រី | នឹង | ផុន | អត្តលេខ ០០៣៨១៨ | មេបញ្ជាការ កងពលតូចថ្មើរជើងលេខ ២១ |
| ៤២ - | ឧត្តមសេនីយ៍ត្រី | ឈុន | ញ៉ឹប | អត្តលេខ ០០៣៨៤៧ | មេបញ្ជាការរង យោធភូមិភាគទី ៥ |
| ៤៣ - | ឧត្តមសេនីយ៍ត្រី | នួន | ប៉ាត់ | អត្តលេខ ០០០៣៨៦ | មេបញ្ជាការរង និងជានាយសេនាធិការយោធភូមិភាគទី ១ |
| ៤៤ - | វរសេនីយ៍ឯក | មាស | លី | អត្តលេខ ០០០៥៣៨ | នាយករង នាយកដ្ឋានបុគ្គលិក |
| ៤៥ | វរសេនីយ៍ឯក | ណុប | រតនា | អត្តលេខ ០០១៨៨១ | នាយករង ទីចាត់ការបុគ្គលិកអគ្គបញ្ជាការដ្ឋាន |
| ៤៦ - | វរសេនីយ៍ឯក | ឡៅ | ហ៊ីន | អត្តលេខ ០០១៤០១ | នាយកការិយាល័យគ្រប់គ្រងឋានន្តរសក្តិ និងតែងតាំងផ្លាស់ប្តូរ |
| ៤៧ - | វរសេនីយ៍ឯក | ជួប | សំបូរ | អត្តលេខ ០០១៤១៣ | នាយកការិយាល័យផែនការ នាយកដ្ឋានបុគ្គលិក |
| ៤៨ - | វរសេនីយ៍ឯក | គង់ | ចណ្ឌី | អត្តលេខ ០០១៤០៤ | នាយកការិយាល័យគ្រប់គ្រងស្ថិតិយោធិន និងជាលេខាផ្ទាល់នាយក នាយកដ្ឋានបុគ្គលិក |
| ៤៩ - | វរសេនីយ៍ឯក | ស៊ុំ | ខាំចាន់តារ៉ូ | អត្តលេខ ០០១១៦៦ | នាយករង នាយកដ្ឋានពត៌មាននិងជានាយកការិយាល័យផែនការ |
| ៥០ - | វរសេនីយ៍ឯក | គីម | សុខណ្ណ | អត្តលេខ ០០១៤៧៣ | នាយករង នាយកដ្ឋានកិច្ចការយោធាស៊ីវិល |
| ៥១ - | វរសេនីយ៍ឯក | និត្យ | ម៉ៅឡុង | អត្តលេខ ០០១៤៧២ | នាយមជ្ឈមណ្ឌលបំប៉ន់សុខភាពយោធិនពិការ ៣១៧ |
| ៥២ - | វរសេនីយ៍ឯក | ម៉ៅ | សុខា | អត្តលេខ ០០២០៥៤ | នាយកការិយាល័យរំសាយ ទីចាត់ការបុគ្គលិក |
| ៥៣ - | វរសេនីយ៍ឯក | គួច | ថារី | អត្តលេខ ០០០៦៥២ | នាយកការិយាល័យអត្តសញ្ញាណប័ណ្ណ ទីចាត់ការបុគ្គលិក |
| ៥៤ - | វរសេនីយ៍ឯក | ហាន់ | សុខណ្ណ | អត្តលេខ ០០១៨៧៨ | នាយកការិយាល័យតែងតាំងផ្លាស់ប្តូរ ទីចាត់ការបុគ្គលិក |
| ៥៥ - | វរសេនីយ៍ឯក | ចាន់ | នន់ខិឡា | អត្តលេខ ០០៣៤៥៩ | នាយកការិយាល័យបុគ្គលិក ទីចាត់ការបុគ្គលិក |
| ៥៦ - | វរសេនីយ៍ឯក | ឌួច | សុផាត | អត្តលេខ ០០១៨៩១ | នាយកការិយាល័យឥស្សរិយយស ទីចាត់ការបុគ្គលិក |
| ៥៧ - | វរសេនីយ៍ឯក | សៅ | សុជាតិ | អត្តលេខ ០០០៨២១ | នាយរងសេនាធិការ យោធភូមិភាគទី ៥ |
| ៥៨ - | វរសេនីយ៍ឯក | ចាន់ | សុភាន់ធុន | អត្តលេខ ០០០៨០០ | មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងខេត្តពោធិ៍សាត់ |
| ៥៩ - | វរសេនីយ៍ឯក | យ៉ាស់ | សុទ្ធឡី | អត្តលេខ ០០១០៣១ | មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងខេត្តបន្ទាយមានជ័យ |
| ៦០ - | វរសេនីយ៍ឯក | យឹម | ឡាង | អត្តលេខ ០០៣៥៤៥ | នាយរងសេនាធិការ យោធភូមិភាគទី ៥ |
| ៦១ - | វរសេនីយ៍ឯក | ជា | រស់ | អត្តលេខ ០០០៣៥៨ | មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងខេត្តបាត់ដំបង |
| ៦២ - | វរសេនីយ៍ឯក | យិន | សុខា | អត្តលេខ ០០១៦២០ | នាយករង វិទ្យាស្ថានយោធាកម្ពុជា |
| ៦៣ - | វរសេនីយ៍ឯក | អ៊ុត | សាខន | អត្តលេខ ០០១៨៨៣ | នាយកការិយាល័យសោធននិវត្តន៍ ទីចាត់ការបុគ្គលិក |
| ៦៤ - | វរសេនីយ៍ឯក | មិន | នីម | អត្តលេខ ០០០៣៦០ | មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងខេត្តកំពង់ស្ពឺ |
| ៦៥ - | វរសេនីយ៍ឯក | គង | សំអឿន | អត្តលេខ ០០០៣៦៣ | មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងខេត្តតាកែវ |
| ៦៦ - | វរសេនីយ៍ឯក | អ៊ុង | ចណ្ណារិទ្ធ | អត្តលេខ ០០០៤៤៧ | មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងខេត្តកំពត |
| ៦៧ - | វរសេនីយ៍ឯក | ជន | សុផល | អត្តលេខ ០០០៥៤២ | មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងក្រុងកែប |
| ៦៨ - | វរសេនីយ៍ឯក | ឆេ | ខា | អត្តលេខ ០០០៥៥៨ | មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ |
| ៦៩ - | វរសេនីយ៍ឯក | យន្ត | មីន | អត្តលេខ ០០០៥៥៣ | មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងខេត្តកោះកុង |

| | | | | | | |
|---|---|---|---|---|---|---|
| ៧០ - | វរសេនីយ៍ឯក | ណា | សាន់ | អត្តលេខ | ០០០៥៧៨ | នាយកការិយាល័យគោលរបប នាយកដ្ឋានសោធននិវត្តន៍ |
| ៧១ - | វរសេនីយ៍ឯក | ញ៉ឹម | សុខណ្ណ | អត្តលេខ | ០០៣៣៩៨ | នាយការិយាល័យទី១ បញ្ជាការដ្ឋានកងទ័ពជើងអាកាស |
| ៧២ - | វរសេនីយ៍ឯក | តុល | ថិល | អត្តលេខ | ០០១៨៧១ | នាយរងការិយាល័យទី១ បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៧៣ - | វរសេនីយ៍ឯក | ភឿត | ផៃ | អត្តលេខ | ០០០៤៨០ | នាយរងការិយាល័យទី១ បញ្ជាការដ្ឋានកងទ័ពជើងគោក |
| ៧៤ - | វរសេនីយ៍ឯក | មិន | សុខណ្ណារ៉ា | អត្តលេខ | ០០១៩៩៩ | នាយរងការិយាល័យទី៥ បញ្ជាការដ្ឋានកងទ័ពជើងគោក |
- យោងអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា។
- យោងអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើ អនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទិ ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧។
- អនុលោមតាមតំរូវការចាំបាច់

40

# សម្រេច

**ប្រការ១:** បង្កើតក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយ ចំពោះគំរោងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ចម ប្រសិទ្ធ** | រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម និងជាអនុប្រធាន "ក.អ.ក" | ប្រធាន |
| ២- | ឯកឧត្តម **គង់ វិបុល** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន"ក.អ.ក" | អនុប្រធាន |
| ៣- | ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤- | ឯកឧត្តម **សួន សិទ្ធី** | អគ្គលេខាធិការ គណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ៥- | ឯកឧត្តម **សេង លឹមនៅ** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- | ឯកឧត្តម **រស់ រ៉េន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៧- | ឯកឧត្តម **ប្រាជ្ញ ស៊ុន** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- | ឯកឧត្តម **អ៊ិត ណូឌី** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩- | ឯកឧត្តម **អ៊ុក ចាន់** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០- | ឯកឧត្តម **សក់ សេដ្ឋា** | អគ្គនាយករដ្ឋបាលក្រសួងមហាផ្ទៃ | សមាជិក |
| ១១- | ឯកឧត្តម **ឱុច ទននិត្យ** | អគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១២- | ឯកឧត្តម **សាយ ហាក់** | អភិបាលក្រុងព្រះសីហនុ | សមាជិក |
| ១៣- | លោក **អន សុផាណារ៉ា** | ប្រធាននាយកដ្ឋាន នៃគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ១៤- | លោក **ពត ណារិន** | ប្រធាននាយកដ្ឋាន នៃគណៈកម្មាធិការវិនិយោគកម្ពុជា | លេខា |

សមាជិកក្រុមការងារទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំអោយបានទៀងទាត់តាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

**ប្រការ២:** ក្រុមការងារដូចមានចែងក្នុងប្រការ១ ខាងលើ មានភារកិច្ចដូចខាងក្រោម :

- ចុះសិក្សាស្រាវជ្រាវដល់ទីកន្លែងជាក់ស្តែង ដើម្បីមានមូលដ្ឋានក្នុងការពិនិត្យពិចារណាលើប្លង់មេ-របាយការណ៍ស្តីពីហេតុប៉ះពាល់បរិស្ថាន ដែលផ្តល់ដោយសាមីក្រុមហ៊ុន និងសិក្សាពីផលប្រយោជន៍សេដ្ឋកិច្ច សំដៅជំរុញដោះស្រាយការងាររៀបចំកិច្ចព្រមព្រៀងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹមអោយបានឆាប់ ។
- តាមដានជាប្រចាំ នូវរាល់ការអនុវត្តន៍ការងាររបស់ក្រុមហ៊ុន តាមជំហានទីមួយៗ ដែលមានចែងក្នុងអនុស្សារណៈចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០២ ។
- ធ្វើរបាយការណ៍ជាប្រចាំពីសកម្មភាពការងារ និងពីទិសដៅត្រូវអនុវត្តបន្ត ជូនប្រមុខរាជរដ្ឋាភិបាល ។
- លើកសំណើសុំការសំរេចពីរាជរដ្ឋាភិបាល ចំពោះករណីដែលហួសពីសមត្ថកិច្ចរបស់ខ្លួន ។

**ប្រការ៣:** ក្រុមការងារនេះ មានការិយាល័យអចិន្ត្រៃយ៍តាំងនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមានសិទ្ធិប្រើប្រាស់ជាផ្លូវការនូវត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងកិច្ចដំណើរការរបស់ខ្លួន ។

**ប្រការ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី-សហរដ្ឋមន្ត្រីក្រសួងក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងទេសចរណ៍-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន-រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ-រដ្ឋមន្ត្រី ក្រសួងបរិស្ថាន-ប្រធាន"ក.អ.ក"-រដ្ឋមន្ត្រីគ្រប់ក្រសួង-ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧០ . សសរ

# សេចក្ដីសំរេច

# ស្ដីពី

# ការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រី កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ាន (AMBDC) លើកទី៤

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## <u>សំរេច</u>

**ប្រការ១** : បង្កើត គណៈកម្មការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ានលើកទី៤ ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្ដម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ជាប្រធាន

២- ឯកឧត្ដម **ឃឹ តាំងលឹម** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ជាអនុប្រធាន

៣- ឯកឧត្ដម **មិន ឃិន** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ ជាសមាជិក

៤- ឯកឧត្តមនាយឧត្តមសេនីយ៍ **ហុក ឡុងឌី** អគ្គស្នងការនគរបាលជាតិ ជាសមាជិក

៥- ឯកឧត្តម **អ៊ុច គឹមអន** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៦- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៧- ឯកឧត្តម **អ៊ូ ឱ្យហារ** រដ្ឋលេខាធិការក្រសួងផែនការ ជាសមាជិក

៨- ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ ជាសមាជិក

៩- ឯកឧត្តម **គឹម ស៊ីថន** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ជាសមាជិកអចិន្ត្រៃយ៍

១០- ឯកឧត្តម **ចាប ញ៉ាលីខុធ** អភិបាលខេត្តសៀមរាប ជាសមាជិក

១១- ឯកឧត្តមឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាសមាជិក

១២- ឯកឧត្តមឧត្តមសេនីយ៍ទោ **ជា ម៉ន** មេបញ្ជាការយោធភូមិភាគទី៤ ជាសមាជិក

១៣- ឯកឧត្តម **ហ៊ូ តាំងអេង** អគ្គនាយកក្រសួងផែនការ ជាសមាជិក

**ប្រការ២** : គណៈកម្មការរៀបចំកិច្ចប្រជុំនេះមានភារកិច្ចដូចតទៅ :

ក-រៀបចំខ្លឹមសារ និងឯកសារប្រជុំដាក់ឆ្លងយោបល់គណៈរដ្ឋមន្ត្រី

ខ-រៀបចំកម្មវិធីប្រជុំ និងពិធីការអោយបានសមស្រប

គ- រៀបចំគំរោងចំណាយសំរាប់រៀបចំកិច្ចប្រជុំនេះ រួចលើកសំណើសុំថវិកាពីរាជរដ្ឋាភិបាល

ឃ- សំរបសំរួល រៀបចំការពារសន្តិសុខជូនគណៈប្រតិភូ និងសមាជិកអង្គប្រជុំអោយមានសុវត្ថិភាពល្អ

ង- ចាត់ចែងការសំដែងសិល្បៈប្រពៃណី ជូនគណៈប្រតិភូក្នុងក្របខ័ណ្ឌជាតិ និងភាគរៈអន្តរជាតិ

ច- សំរបសំរួល និងចាត់ចែងការធ្វើដំណើរទស្សនាចរជូនគណៈប្រតិភូ ក្រោយកិច្ចប្រជុំ តាមកម្មវិធីដែលបានគ្រោងទុក

ឆ- សំរបសំរួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីធ្វើការផ្សព្វផ្សាយពីកិច្ចប្រជុំនេះជូនប្រមុខរាជរដ្ឋាភិបាល

ជ-រាយការណ៍ជាបន្តបន្ទាប់អំពីការចាត់ចែង និងសុំយោបល់ប្រមុខរាជរដ្ឋាភិបាលលើខ្លឹមសាររបស់អង្គប្រជុំក្នុងករណីដែលមានការប្រែប្រួល ។

**ប្រការ៣** : គណៈកម្មការនេះមានសិទ្ធិអញ្ជើញមន្ត្រីជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធនានា មកចូលរួមប្រជុំដើម្បីពិភាក្សា និងដោះស្រាយការងារដែលចាំបាច់ ។

**ប្រការ៤** : គណៈកម្មការនេះមានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញផ្សេងទៀត តាមការចាំបាច់ ។

**ប្រការ៥** : គណៈកម្មការនេះមានសិទ្ធិ ប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម ហើយត្រូវរំសាយជាស្វ័យប្រវត្តិ បន្ទាប់ពីចប់ភារកិច្ច ។

**ប្រការ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ អភិបាលខេត្តសៀមរាប រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង និងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម ដែលមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ចម ប្រសិទ្ធ**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៣៦២ សហវ.ប្រក.

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០២

## ប្រកាស

## ស្តីពី

## ការបង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាករ រាជធានីភ្នំពេញ

---

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/ រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ
- យោងចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០២ លើសំណើលេខ ១២៩១ សហវ ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សំរេច

**ប្រការ១ :** បង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាករ រាជធានីភ្នំពេញ ថ្នាក់ប្រហាក់ប្រហែលមន្ទីរនានាជុំវិញខេត្ត ក្រុង ដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានការិយាល័យកណ្តាលបោះប្រចាំនៅទីចាត់ការគយនិងរដ្ឋាករ ។

**ប្រការ២ :** សាខាគយនិងរដ្ឋាកររាជធានីភ្នំពេញដឹកនាំដោយប្រធានសាខាមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ ៣** : សាខាគយនិងរដ្ឋាករ រាជធានីភ្នំពេញ មានភារកិច្ចដូចតទៅ ៖

១- គ្រប់គ្រង ដឹកនាំបញ្ជាតាមឋានានុក្រមដោយផ្ទាល់ លើបណ្តាទីស្នាក់ការគយនិងរដ្ឋាករប្រចាំតាមបណ្តាខ័ណ្ឌ ស្រុក និមួយៗ នៃរាជធានីភ្នំពេញ ។

២- ចាត់ចែង រៀបចំ ផ្សព្វផ្សាយតាមរូបភាពនានាដល់អាជីវករ និងបុគ្គលពាក់ព័ន្ធទាំងឡាយឱ្យយល់ដឹងទាន់ពេលវេលាពីភាពស្របច្បាប់នៃទំនិញនាំចូល និងការទទួលខុសត្រូវចំពោះមុខច្បាប់រាល់ពេលរកឃើញមានការចូលរួមគេចវេសកាតព្វកិច្ចពន្ធ អាករដោយផ្ទាល់ ឬ ដោយប្រយោលការធ្វើចរាចរចែកចាយសន្និធិទំនិញនាំចូលដោយល្មើសនានាក្នុងមូលដ្ឋាន អាជីវកម្មដ្ឋាន ឬ លំនៅដ្ឋាននិមួយៗ ។

៣- ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគយនានាក្នុងភូមិសាស្ត្រគ្រប់គ្រងរបស់រាជធានីភ្នំពេញ លើទំនិញនាំចូលដោយគេចពន្ធតាមគ្រប់រូបភាពដែលកំពុងសន្និធិចរាចរ ចែកចាយ ឬ កំពុងប្រើប្រាស់តាមបណ្តាអាជីវកម្មដ្ឋាន ភណ្ឌាគារទំនិញ មូលដ្ឋានផលិតកម្ម ឬលំនៅដ្ឋាននានា ដោយអនុលោមតាមនីតិវិធីច្បាប់ និងបទបញ្ញត្តិនានាជាធរមាន ។

៤- ចុះស្រង់ និងកសាងបញ្ជីជំរឿនស្ថិតិ អាជីវកម្មដ្ឋានលក់ដុំ លក់រាយ ភណ្ឌាគារសន្និធិទំនិញនានា ដែលស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងពិសេស រួមមាន យានយន្តគ្រប់ប្រភេទ ផលិតផលគេលសិលា ភេសជ្ជៈ ព្រមទាំងទំនិញរសើបមួយចំនួនទៀតដែលនឹងកំណត់ដោយទីចាត់ការគយនិងរដ្ឋាករ ។

៥- អនុវត្តតាមភារកិច្ចផ្សេងៗដែលនឹងកំណត់តាមការចាំបាច់នានា ដោយទីចាត់ការគយនិងរដ្ឋាករស្របតាមបញ្ញត្តិច្បាប់ជាធរមាន ។

៦- ប្រើប្រាស់កំលាំងគយនិងរដ្ឋាករក្រោមឱវាទ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រចាំមូលដ្ឋាន ជាពិសេសអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ក្នុងករណីចាំបាច់ ដើម្បីសំរេចឱ្យបាននូវភារកិច្ចដូចរៀបរាប់ខាងលើ ។

**ប្រការ ៤** : ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥** : អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ ( ដើម្បីជូនជ្រាប )
- សាលាក្រុងភ្នំពេញ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ( ដើម្បីសហការអនុវត្ត )
- ដូចប្រការ៥ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៣៦៤ សហវ.ប្រក.

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០២

# ប្រកាស

## ស្តីពី

## ការបង្កើត និងដាក់ឱ្យដំណើរការនូវទីស្នាក់ការគយនិងរដ្ឋាករមួយចំនួន តាមបណ្តាខំណ្ឌនានានៃ រាជធានីភ្នំពេញ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ
- យោងចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០២ លើសំណើលេខ ១២៩១ សហវ ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាករ រាជធានីភ្នំពេញ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សំរេច

**ប្រការ១ :** បង្កើត និងដាក់ឱ្យដំណើរការនូវទីស្នាក់ការគយនិងរដ្ឋាករមួយចំនួនដែលបានបោះប្រចាំតាមបណ្តាខ័ណ្ឌនៃ រាជធានីភ្នំពេញ ថ្នាក់ប្រហាក់ប្រហែល ការិយាល័យនានាជុំវិញខេត្ត ក្រុង ដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់សាខាគយនិងរដ្ឋាករ រាជធានីភ្នំពេញមានដូចខាងក្រោម៖

១- ទីស្នាក់ការគយនិងរដ្ឋាករ ខ័ណ្ឌ ៧ មករា
២- ទីស្នាក់ការគយនិងរដ្ឋាករ ខ័ណ្ឌ ដូនពេញ
៣- ទីស្នាក់ការគយនិងរដ្ឋាករ ខ័ណ្ឌ ចំការមន
៤- ទីស្នាក់ការគយនិងរដ្ឋាករ ខ័ណ្ឌ ទួលគោក
៥- ទីស្នាក់ការគយនិងរដ្ឋាករ ខ័ណ្ឌ មានជ័យ
៦- ទីស្នាក់ការគយនិងរដ្ឋាករ ខ័ណ្ឌ ដង្កោ
៧- ទីស្នាក់ការគយនិងរដ្ឋាករ ខ័ណ្ឌ ឫស្សីកែវ

**ប្រការ ២** : ទីស្នាក់ការគយនិងរដ្ឋាករនិមួយៗដូចមានចែងក្នុងប្រការ១ខាងលើដឹកនាំដោយប្រធានទីស្នាក់ការមួយរូប និងមានអនុប្រធានទីស្នាក់ការមួយចំនួនជាជំនួយការ ។

**ប្រការ ៣** : ទីស្នាក់ការគយនិងរដ្ឋាករនិមួយៗតាមបណ្តាខ័ណ្ឌនៃ រាជធានីភ្នំពេញ មានភារកិច្ចដូចតទៅ ៖

១- ចុះស្រង់ កសាងនិងកែសំរួលបញ្ជីជំរឿនស្ថិតិ អាជីវកម្មដ្ឋានលក់ដុំ លក់រាយ ភណ្ឌាគារសន្និធិទំនិញនានា ដែលស្ថិតក្រោមប្រពន្ធ័គ្រប់គ្រងពិសេសរួមមាន យានយន្តគ្រប់ប្រភេទ ផលិតផលតេលសិលា ភេសជ្ជៈ ព្រមទាំងទំនិញរសើបមួយចំនួនទៀតដែលកំណត់ដោយទីចាត់ការគយនិងរដ្ឋាករ ។

២- ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគយនានាក្នុងភូមិសាស្ត្រគ្រប់គ្រងរបស់រាជធានីភ្នំពេញ លើទំនិញនាំចូលដោយគេចពន្ធតាមគ្រប់រូបភាពដែលកំពុងសន្និធិចរាចរ ចែកចាយ ឬ កំពុងប្រើប្រាស់តាមបណ្តាអាជីវកម្មដ្ឋាន ភណ្ឌាគារទំនិញ មូលដ្ឋានផលិតកម្ម ឬលំនៅដ្ឋាននានា ដោយអនុលោមតាមនីតិវិធីច្បាប់ និងបទបញ្ញត្តិនានាជាធរមាន ។

៣- អនុវត្តតាមភារកិច្ចផ្សេងៗដែលនឹងកំណត់តាមការចាំបាច់នានា ដោយទីចាត់ការគយនិងរដ្ឋាករស្របតាមបញ្ញត្តិច្បាប់ជាធរមាន ។

៤- ប្រើប្រាស់កំលាំងគយនិងរដ្ឋាករក្រោមឱវាទ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រចាំមូលដ្ឋាន ជាពិសេសអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ក្នុងករណីចាំបាច់ ដើម្បីសំរេចឱ្យបាននូវភារកិច្ចដូចរៀបរាប់ខាងលើ ។

**ប្រការ ៤** : ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥** : អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ពន្ធ័ផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ ( ដើម្បីជូនជ្រាប )
- សាលាក្រុងភ្នំពេញ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ( ដើម្បីសហការអនុវត្ត )
- ដូចប្រការ៥ ( ដើម្បីអនុវត្ត )
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៧២សហវ.វស

# ប្រកាស

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យវាយតំលៃ លើផលប៉ះពាល់ដល់ប្រជារាស្ត្រ ពីគំរោងសាងសង់កំណាត់ផ្លូវជាតិ លេខ ២ ពីទីរួមខេត្តតាកែវ ( អូរចំបក់ ) ទៅព្រំប្រទល់ កម្ពុជា-វៀតណាម ( ភ្នំដិន )

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស.រកត.១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-បានឃើញលិខិតលេខ ៧០៦សក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ របស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន ។

-បានឃើញលិខិតលេខ ១៥០១ សហវ.វស ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-បានឃើញលិខិតលេខ ៨៣២ សក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០២ របស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន ។

-យោងតាមតំរូវការចាំបាច់នៃការងារ

## សំរេច

**ប្រការ ១:** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យវាយតំលៃលើផលប៉ះពាល់ដល់ប្រជារាស្ត្រពីគំរោងសាងសង់កំណាត់ផ្លូវជាតិ លេខ ២ ពីទីរួមខេត្តតាកែវ ( អូរចំបក់ ) ទៅព្រំប្រទល់កម្ពុជា-វៀតណាម ( ភ្នំដិន ) ។

**ប្រការ ២:** គណៈកម្មការអន្តរក្រសួងនេះ មានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១. ឯកឧត្តម ញាណ ឡេង | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | ជាប្រធាន |
| ២. លោក ចាន់ សុធី | ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៣. លោក ប៉ោ យុទ្ធថា | ប្រធានការិយាល័យសហប្រតិបត្តិការទ្វេភាគី | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៤. លោក បែន ដារ៉ាមុនី | អនុប្រធានការិយាល័យសហប្រតិបត្តិការទ្វេភាគី | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៥. លោក ជិន រ័ត្នមុនី | ជំនួយការឯកឧត្តមប្រធានគណៈកម្មការអន្តរក្រសួង | | សមាជិក |
| ៦. លោកស្រី អ៊ុក សុមាលី | មន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន | | សមាជិក |
| ៧. លោក ខាន់ រ៉ា | មន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន | | សមាជិក |
| ៨. លោក យស់ សុវណ្ណា | មន្ត្រីការិយាល័យសហប្រតិបត្តិការទ្វេភាគី | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

៩. លោក សារុម សុធឿន មន្ត្រីការិយាល័យសហប្រតិបត្តិការទ្វេភាគី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១០. លោក ឃុន ផលគង់ មន្ត្រីនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

**ប្រការ ៣:** គណៈកម្មការអន្តរក្រសួង មានភារកិច្ចចុះពិនិត្យដល់ទីកន្លែងធ្វើស្ថិតិលើផលប៉ះពាល់ដល់ប្រជារាស្ត្រដែលស្ថិតនៅតាមគំរោងសាងសង់កំណាត់ផ្លូវជាតិលេខ ២ ពីទីរួមខេត្តតាកែវ ( អូរចំបក់ ) ទៅព្រំប្រទល់កម្ពុជា-វៀតណាម ( ភ្នំដិន ) រួចហើយធ្វើការវាយតំលៃអោយបានសមស្រប ដើម្បីមានមូលដ្ឋានក្នុងការចំណាយថវិកាបដិភាគសំរាប់គំរោងការនេះ។

**ប្រការ ៤:** ក្រសួងសាធារណៈការ និង ដឹកជញ្ជូន នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មន្ត្រីដូចមានចែងក្នុងប្រការ ២ មានភារកិច្ចអនុវត្តន៍ប្រកាសនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០០២

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសាធារណៈការ និងដឹកជញ្ជូន
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រ កម្ពុជា
*Kingdom Of Cambodia*

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
Land Appraisal and Valuation Committee

លេខ :...០០៧......សសរ.សហវ.ពដ

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០២

# សេចក្តីសំរេច

## ស្តីពី

## ការកែប្រែសមាសភាពអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
## នៅខេត្ត រតនគិរី

~~~~~~~

## ប្រធានគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១-នស-៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស-រកម-០២៩៧-០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ ៥៨-អនក្រ-ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
~~~~~~~

- បានឃើញប្រកាសលេខ ៧៨៤-ប្រក-សហវ-ពដ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ១៩៩៦ ស្តីពីការកំណត់មេគុណសម្រាប់អនុវត្តក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសំរេចលេខ ០០៨-សសរ-សហវ-ពដ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ១៩៩៨ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ៣៩៣ ប្រក.សហវ.ពដ ចុះថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ១៩៩៩ ស្តីពីការកែប្រែសមាសភាពគណៈកម្មការវាយតម្លៃដីធ្លីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសំរេចលេខ ០០២ សសរ.ពដ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០០០ ស្តីពីការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅខេត្តរតនគិរី ខេត្តព្រះវិហារ និង ក្រុងប៉ៃលិន
- យោងតាមលិខិតលេខ ៤០៨/០២ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០២ របស់សាលាខេត្តរតនគិរី ស្តីពីការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ។
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់នៅខេត្តរតនគិរី ។

## សំរេច

**ប្រការ១** : សមាសភាពនៃអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅខេត្តរតនគិរី ដែលមានចែងនៅក្នុងប្រការ១ លេខរៀងទី១នៃសេចក្តីសំរេចលេខ ០០២ សសរ.ពដ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០០ ស្តីពីការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ខេត្តរតនគិរី ខេត្តព្រះវិហារ និង ក្រុងប៉ៃលិន ត្រូវបានធ្វើការកែប្រែដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម **មួង ច័យ** | អភិបាលរងទី២ខេត្ត | ជាប្រធាន |
| ២- លោក **ខាំ សែ** | ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្ត | ជាអនុប្រធាន |
| ៣- លោក **ថៅ នួន** | ប្រធានសាខាពន្ធដារខេត្ត | ជាសមាជិកអចិន្ត្រៃយ៍ |
| ៤- លោក **ទឹម ស៊ិណាត** | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត | ជាសមាជិកអចិន្ត្រៃយ៍ |
| ៥- លោក **ឆាយ ទុិត** | ប្រធានមន្ទីរកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទខេត្ត | ជាសមាជិក |
| ៦- លោក **ក្មុយ ជៀចទឺនសៃ** | នាយក្រុមហិរញ្ញវត្ថុសាលាខេត្ត | ជាសមាជិក |
| ៧- លោក **អភិបាលស្រុកគ្រប់ស្រុកនូនវាំងខេត្ត** | | ជាសមាជិក |

**ប្រការ២** : អនុគណៈកម្មការមានភារកិច្ច :

- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បង្កើតបញ្ជីដីត្រូវជាប់ពន្ធ តាមតំបន់ក្នុងខេត្ត-ក្រុង
- លើកគំរោងតម្លៃដីក្នុងមួយម៉ែត្រក្រឡា គិតតាមតំបន់នីមួយៗក្នុងខេត្ត-ក្រុង ដើម្បីជាមូលដ្ឋានគណនាប្រាក់ពន្ធដាក់ជូនគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ពិនិត្យនិងសំរេច
- ផ្តល់មតិចំពោះរឿងវិវាទនានា ដែលពាក់ព័ន្ធទៅនឹងដីមិនបានប្រើប្រាស់ ។

**ប្រការ៣** : អនុគណៈកម្មការអាចរៀបចំបង្កើតក្រុមជំនួយការមួយ ដើម្បីធានានិរន្តភាពក្នុងប្រតិបត្តិការរបស់អនុគណៈកម្មការ។

**ប្រការ៤ :** សមាជិកអនុគណៈកម្មការត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ ។

**ប្រការ៥ :** អនុគណៈកម្មការត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការ និង ត្រូវរាយការណ៍ជាប្រចាំតាមខែនីមួយៗ មកគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ៦ :** ឯកឧត្តម អស់លោក ដូចមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រធានគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់**

**កែវ ពិបុល**

**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

***កន្លែងទទួល :***

- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលាខេត្តរតនគីរី "ដើម្បីជូនជ្រាបជាពត៌មាន"
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ៩៤០ MoC / M 2002

# ប្រកាស
## ស្តីពី
## ការបង្កើតអនុគណៈកម្មការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រី កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ាន (AMBDC) លើកទី៤

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំង នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញសេចក្តីសំរេចលេខ ៣០ សសរ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើត គណៈកម្មការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រី កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ាន ( AMBDC ) លើកទី៤

## សំរេច

**ប្រការ១** : បង្កើត ***អនុគណៈកម្មការសន្តិសុខ*** សំរាប់រៀបចំកិច្ចប្រជុំរដ្ឋមន្ត្រី កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ានលើកទី៤ ដែលរួមមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **អ៊ុំ អឿន** អភិបាលរងទី១ ខេត្តសៀមរាប ជាប្រធាន

| | | |
|---|---|---|
| ២- ឯកឧត្តម **គីម ស៊ីថន** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | ជាអនុប្រធាន |
| ៣- ឧត្តមសេនីយ៍ត្រី **កែវ ធី** | មេបញ្ជាការរង យោធភូមិភាគទី៤ | ជាអនុប្រធាន |
| ៤- ឧត្តមសេនីយ៍ត្រី **ស៊ឹម សុផល** | ប្រធាននាយកដ្ឋានអង្គរក្ស ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៥- ឧត្តមសេនីយ៍ត្រី **អ៊ុយ សុភាព** | មេបញ្ជាការកងពលលេខ១១ | ជាសមាជិក |
| ៦- វរសេនីយ៍ឯក **នួន បូផល** | ស្នងការនគរបាលខេត្តសៀមរាប | ជាសមាជិក |
| ៧- វរសេនីយ៍ឯក **ឃឹម ម៉ុនសុខ** | មេបញ្ជាការតំបន់សឹករងខេត្តសៀមរាប | ជាសមាជិក |
| ៨- វរសេនីយ៍ឯក **តាន់ ចាយ** | ស្នងការនគរបាលពិសេសរក្សាបឹតិកភ័ណ្ឌ | ជាសមាជិក |
| ៩- វរសេនីយ៍ឯក **ម៉ន សារ៉ុន** | មេបញ្ជាការកងរាជអាវុធហត្ថខេត្តសៀមរាប | ជាសមាជិក |
| ១០- លោក **សួស វណ្ណា** | ប្រធាននាយកដ្ឋានបុគ្គលិក ក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ១១- លោក **ឈឹម ម៉ា** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តសៀមរាប | ជាសមាជិក |

អនុគណៈកម្មការសន្តិសុខ មានភារកិច្ចដូចខាងក្រោម :

- ការពារសុវត្ថិភាពជូនគណៈប្រតិភូ
- រៀបចំផ្លាកសញ្ញាសំគាល់ផ្សេងៗ
- រៀបចំសណ្តាប់ធ្នាប់ជូនគណៈប្រតិភូ

**ប្រការ២** : បង្កើត **អនុគណៈកម្មការពិធីការ** សំរាប់រៀបចំកិច្ចប្រជុំរដ្ឋមន្ត្រី កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ានលើកទី៤ ដែលរួមមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **គីម ស៊ីថន** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | ជាប្រធាន |
| ២- ឯកឧត្តម **ម៉ិច សុខិន** | អភិបាលរងទី៣ ខេត្តសៀមរាប | ជាអនុប្រធាន |
| ៣- លោក **ស្មៀន ម៉ុនធុជ** | អនុប្រធាននាយកដ្ឋានពិធីការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |
| ៤- លោក **ស៊ុត តារា** | ប្រធាននាយកដ្ឋានកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៥- លោក **លី ផាវណ្ណា** | ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | ជាសមាជិក |
| ៦- លោក **ធន ទីរៈ** | អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស | ជាសមាជិក |
| ៧- លោក **ជួន វន** | អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស | ជាសមាជិក |
| ៨- លោក **ឃឹម សិរីវឌ្ឍ** | អនុប្រធាននាយកដ្ឋានបុគ្គលិក | ជាសមាជិក |
| ៩- លោក **ឌេស ហេង** | អនុប្រធាននាយកដ្ឋានពិធីការ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ | ជាសមាជិក |

១០- លោក **គុខ លុណា** ប្រធានការិយាល័យពិធីការ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

១១- លោក **ឃួន ច័ន្ទសារិទ្ឋ** អនុប្រធានមន្ទីរពាណិជ្ជកម្ម ខេត្តសៀមរាប ជាសមាជិក

១២- លោក **ម៉ូ ច័ន្ទតិរុ** ប្រធានការិយាល័យអាស៊ាន ជាសមាជិក

អនុគណៈកម្មការពិធីការ មានភារកិច្ចដូចខាងក្រោម :

- រៀបចំទទួល និងជូនដំណើរគណៈប្រតិភូ
- រៀបចំកន្លែងស្នាក់នៅ កន្លែងពិសារភោជនាហារ កន្លែងជប់លៀងជូនគណៈប្រតិភូ
- រៀបចំទិវាសិល្បៈជូនគណៈប្រតិភូ
- រៀបចំកន្លែងប្រជុំជូនគណៈប្រតិភូ
- រៀបចំដំណើរទស្សនៈកិច្ចកំសាន្តជូនគណៈប្រតិភូ

**ប្រការ៣** : បង្កើត **អនុគណៈកម្មការហិរញ្ញវត្ថុ ផ្គត់ផ្គង់ និងដឹកជញ្ជូន** សំរាប់រៀបចំកិច្ចប្រជុំរដ្ឋមន្ត្រី កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ានលើកទី៤ ដែលរួមមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **កែម សុខណៃ** អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម ជាប្រធាន

២- ឯកឧត្តម **ម៉ា ដារុង** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម អនុប្រធាន

៣- លោក **ម៉ៅ សុគិន** ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ជាសមាជិក

៤- លោក **ស៊ីន សុថា** អនុប្រធាននាយកដ្ឋានជំរុញការនាំចេញ ជាសមាជិក

៥- លោក **ម៉ា រត្នសារ** អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ជាសមាជិក

៦- លោក **អ៊ុក នី** អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ជាសមាជិក

៧- លោក **ម៉ៅ ខ្លឹម** អនុប្រធាននាយកដ្ឋានរដ្ឋបាល ជាសមាជិក

៨- លោក **ខិម គោវិត** អនុប្រធានមន្ទីរពាណិជ្ជកម្ម ខេត្តសៀមរាប ជាសមាជិក

៩- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

អនុគណៈកម្មការហិរញ្ញវត្ថុ ផ្គត់ផ្គង់ និងដឹកជញ្ជូន មានភារកិច្ចដូចខាងក្រោម :

- លើកគំរោងចំណាយរួម
- ស្នើសុំថវិកាសំរាប់កិច្ចប្រជុំទាំងមូល
- ធ្វើបញ្ជីចំណាយជាក់ស្តែង និងគ្រប់គ្រងសំភារៈ បរិក្ខារ

- ដឹកជញ្ជូនគណៈប្រតិភូ ពីព្រលានយន្តហោះទៅកន្លែងស្នាក់នៅ ពីកន្លែងស្នាក់នៅទៅកន្លែងប្រជុំ និងទៅកន្លែងផ្សេងៗទៀត តាមការចាំបាច់
- ដឹកជញ្ជូនឥវ៉ាន់ របស់គណៈប្រតិភូ
- ធ្វើបែបបទ ចេញចូលជូនគណៈប្រតិភូ
- ចាត់ចែង និងគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនគណៈប្រតិភូ មធ្យោបាយដឹកជញ្ជូនកំលាំងសន្តិសុខ

**ប្រការ៤** : បង្កើត ***អនុគណៈកម្មការឯកសារ*** សំរាប់រៀបចំកិច្ចប្រជុំរដ្ឋមន្ត្រី កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ានលើកទី៤ ដែលរួមមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ខែក រ៉ាវី** | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | ជាប្រធាន |
| ២- ឯកឧត្តម **ហ៊ូ តាំងអេង** | អគ្គនាយក ក្រសួងផែនការ | អនុប្រធាន |
| ៣- ឯកឧត្តម **ម៉ៅ ថូរ៉ា** | អគ្គនាយកបច្ចេកទេស ក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤- លោក **ពេជ ឫទ្ធី** | អគ្គនាយករងបច្ចេកទេស ក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៥- លោក **អ៊ុយ សម្បត្តិ** | ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៦- លោក **សុខ សុគំរូ** | ប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ | ជាសមាជិក |
| ៧- លោក **ស៊ាង ថៃ** | អនុប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ | ជាសមាជិក |
| ៨- លោក **តឹករ៉េត សំរេច** | អនុប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ | ជាសមាជិក |
| ៩- លោក **ម៉ែន សុទិដ្ឋិ** | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | ជាសមាជិក |
| ១០- លោក **សួន សុខឃីម** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងផែនការ | ជាសមាជិក |
| ១១- លោក **កែ សុវណ្ណ** | ប្រធានការិយាល័យអង្គការពាណិជ្ជកម្មពិភពលោក | ជាសមាជិក |

អនុគណៈកម្មការឯកសារ មានភារកិច្ចដូចខាងក្រោម :

- រៀបចំសន្ទរកថាបើក និងសុន្ទរកថាបិទកិច្ចប្រជុំ
- រៀបចំឯកសារសំរាប់កិច្ចប្រជុំ
- ពិនិត្យខ្លឹមសារនៃឯកសារប្រជុំ
- គ្រប់គ្រង និងបែងចែកឯកសារ
- គ្រប់គ្រងម៉ាស៊ីនកំព្យូទ័រ ម៉ាស៊ីនថតចំលង ម៉ាស៊ីនហ្វាក់ និងសំភារៈផ្សេងៗ

**ប្រការ៥** : អនុគណៈកម្មការនីមួយៗ មានសិទ្ធិជ្រើសរើសមន្ត្រីជំនាញមួយចំនួន ដើម្បីជួយធ្វើការងារក្រោយពីមានការឯកភាព ពីប្រធានគណៈកម្មការ ។

**ប្រការ៦** : សមាជិកអនុគណៈកម្មការនីមួយៗ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៧** : នាយកខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០២

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**និងជាប្រធានគណៈកម្មការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រី**

**កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ានលើកទី៤ ៚**

**ចម ប្រសិទ្ធ**

**ចំលងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងផែនការ
- សាលាខេត្តសៀមរាប
- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- អគ្គស្នងការនគរបាលជាតិ
- អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ
- ដូចប្រការ ៧
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ១៤៦ MoC / M 2002

ភ្នំពេញ,ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០២

# ប្រកាស

## ស្តីពីការដាក់ឱ្យដេញថ្លៃលើកូតា សំលៀកបំពាក់ ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក សំរាប់ប្រើប្រាស់ក្នុងឆ្នាំ២០០២

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤/អនក្រ បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមសុពលភាពនៃការបន្ត កិច្ចព្រមព្រៀងពាណិជ្ជកម្មវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស ឡែន សរសៃសិប្បនិម្មិតធ្វើដោយដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និងសរសៃល្បាយសូត្ររវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលបានចុះហត្ថលេខា កាលពី ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០១
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ១**- គ្រប់រោងចក្រកាត់ដេរទាំងអស់ដែលកំពុងដំណើរការ និងដែលបានចុះបញ្ជី នៅនាយកដ្ឋានប្រពន្ធអនុគ្រោះពាណិជ្ជកម្ម (នាយកដ្ឋាន **GSP** ) នៃក្រសួងពាណិជ្ជកម្ម មុនថ្ងៃទី

០៥ ខែមិថុនា ឆ្នាំ២០០២ ត្រូវបានអញ្ជើញឱ្យមកដេញថ្លៃ តាមប្រភេទផ្សេងៗ នៃ **Quota** ទៅតាមលទ្ធភាពផលិតកម្មរបស់ខ្លួន ។

**ប្រការ២**- រោងចក្រនិមួយៗត្រូវបានអនុញ្ញាតឱ្យដេញថ្លៃ យកបរិមាណតិច ឬស្មើនឹងបរិមាណនៃកូតា ដែលដាក់ ឱ្យដេញថ្លៃ តាមប្រភេទនិមួយៗនៃ **Quota** ដូចតទៅ :

| **ប្រភេទ** | **បរិមាណដេញថ្លៃ (DZ)** | **ប្រភេទ** | **បរិមាណដេញថ្លៃ (DZ)** |
|---|---|---|---|
| ៣៣១/៦៣១ | ២០,០០០ | ៣៤៧/៣៤៨/៦៤៧/៦៤៨ | ៣០០,៩៨៨ |
| ៣៣៤/៦៣៤ | ១៥,៦៦៤ | ៣៥២/៦៥២ | ៣៥,៤៨៦ |
| ៣៣៥/៦៣៥ | ៨,៣២៨ | ៤៣៥ | ២៣៧ |
| ៣៣៨/៣៣៩ | ៤៣០,០០០ | ៤៣៨ | ២,៥៧៣ |
| ៣៤០/៦៤០ | ២៣៥,០០០ | ៤៤៥/៤៤៦ | ០ |
| ៣៤៥ | ៩,៧៤៨ | ៦៣៨/៦៣៩ | ៨៤,០០០ |
| | | ៦៤៥/៦៤៦ | ៥២,១៦០ |

**ប្រការ៣**- ពាក្យសុំដេញថ្លៃនីមួយៗ ត្រូវភ្ជាប់មកជាមួយនូវមូលប្បទានប័ត្រដែលមានការបញ្ជាក់ពីធនាគារ **Certified Check** ដែលមានតំលៃស្មើនឹង ១០% នៃតំលៃដេញថ្លៃសរុប ។ មូលប្បទានប័ត្រនេះ ត្រូវទូទាត់ប្រាក់ជូន គណកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ( Export Quotas Management Committee " EQMC " ) ។ ការបង់ប្រាក់កក់អប្បបរមាមិនគ្រប់ចំនួន ១០% នៃតម្លៃដេញថ្លៃសរុបនឹងចាត់ទុកថា ពាក្យសុំដេញថ្លៃគ្មានប្រសិទ្ធភាព ។ ឧទាហរណ៍ រោងចក្រ **A**

ដេញថ្លៃ ចំនួន ២០ ០០០ ឡូ តំលៃ ៨ ដុល្លា/ឡូ = ១៦០,០០០ ដុល្លា

ទឹកប្រាក់កក់ ១០ % = ១៦,០០០ ដុល្លា

**ប្រការ៤**- ការដេញថ្លៃក្នុងតំលៃខ្ពស់បំផុតតាម **Category** នឹងបានទទួលជ័យជំនះ ។ Quota នឹងត្រូវបានបែងចែកដល់អ្នកដេញថ្លៃ ដែលបានទទួលជោគជ័យរហូតដល់បរិមាណ Quota សរុប ត្រូវបានបែងចែកអស់ ។

**ប្រការ៥**- **Quota** ដែលមិនទាន់បែងចែកនឹងបន្តទុកឱ្យអ្នកដេញថ្លៃក្រោយទៀត ។

**ប្រការ៦-** តំលៃនៃការចូលរួមដេញថ្លៃ នឹងត្រូវទទួលយក ចំពោះរាល់ការបន្ថែមចំនួនទសភាគ ២០ សេន ( ម្ភៃ ) នៃប្រាក់ដុល្លាសហរដ្ឋអាមេរិកលើ ថ្លៃឯកត្តាតាមប្រភេទ នីមួយៗ :

| | | | |
|---|---|---|---|
| **Cat ៣៣១/៦៣១** | **0.30$/dpr** | **Cat ៣៤៧/៣៤៨-៦៤៧/៦៤៨** | **3.00$/doz** |
| **Cat ៣៣៤/៦៣៤** | **3.00$/doz** | **Cat ៣៥២/៦៥២** | **0.50$/doz** |
| **Cat ៣៣៥/៦៣៥** | **3.00$/doz** | **Cat ៤៣៥** | **2.00$/doz** |
| **Cat ៣៣៨/៣៣៩** | **3.00$/doz** | **Cat ៤៣៨** | **2.00$/doz** |
| **Cat ៣៤០/៦៤០** | **1.00$/doz** | **Cat ៤៤៥/៤៤៦** | **0.50$/doz** |
| **Cat ៣៤៥** | **3.00$/doz** | **Cat ៦៣៨/៦៣៩** | **1.00$/doz** |
| | | **Cat ៦៤៥/៦៤៦** | **0.50$/doz** |

**ប្រការ៧-** ពាក្យដេញថ្លៃត្រូវដាក់ជូន ឯកឧត្តមប្រធានគណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ " EQMC " នៃក្រសួងពាណិជ្ជកម្ម ដែលមានទីតាំង នៅអគារជាន់ទី២ លេខ ២០ **B** មហាវិថីព្រះនរោត្តម ។ ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ភ្ជាប់ជាមួយនូវមូលប្បទានប័ត្រ ដែលមានទឹកប្រាក់ចំនួន ១០ % នៃតំលៃដេញថ្លៃសរុប ដាក់ក្នុងស្រោមសំបុត្រនោះ ។

**ប្រការ ៨-** កាលបរិច្ឆេទនៃការបើកស្រោមសំបុត្រដេញថ្លៃ គឺនៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០០២ ចាប់ពីម៉ោង ៨:០០ ព្រឹក នៅទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគារលេខ ២០ អា ជាន់ទី២ មហាវិថីព្រះនរោត្តម ។

**ប្រការ ៩-** កាលបរិច្ឆេទឈប់ទទួលពាក្យដេញថ្លៃគឺនៅថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០០២ វេលាម៉ោង ៥:០០ ល្ងាច ។

**ប្រការ ១០-** លទ្ធផលនៃការដេញថ្លៃ នឹងត្រូវប្រកាសជាសាធារណៈ នៅថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០០២ តាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ១១-** អ្នកចូលរួមដេញថ្លៃ ដែលបានទទួលជោគជ័យ នឹងអាចប្រើប្រាស់កូតាបាន ចាប់ពីថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០២ បន្ទាប់ពីបានទូទាត់តំលៃដេញថ្លៃ ដែលនៅសេសសល់ ៩០ % រួចហើយ ។

**ប្រការ ១២**- អ្នកដេញថ្លៃដែលបានទទួលជោគជ័យ ប៉ុន្តែខកខានមិនបានទទួលយកកូតារបស់ខ្លួនទៅប្រើប្រាស់ នឹងត្រូវរឹបអូសយកប្រាក់កក់ ១០% ហើយបរិមាណកូតានោះ នឹងបន្តទុកសំរាប់ដេញថ្លៃលើកក្រោយទៀត ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធិក្នុងការ មិនអនុញ្ញាតឱ្យក្រុមហ៊ុននោះ ចូលរួមដេញថ្លៃកូតា លើកក្រោយៗទៀតឡើយ ។

**ប្រការ ១៣**- អ្នកចូលរួមដេញថ្លៃ ដែលមិនបានទទួលជោគជ័យ នឹងត្រូវបានផ្តល់ជូនវិញនូវប្រាក់កក់ ១០% របស់ខ្លួន ចាប់ពីថ្ងៃបន្ទាប់ពីថ្ងៃដេញថ្លៃតទៅ ។

**ប្រការ ១៤**- Quota ដែលបានទទួល តាមរយៈការដេញថ្លៃនេះ ប្រើប្រាស់បានសំរាប់ឆ្នាំសារពើពន្ធ ២០០២ តែប៉ុណ្ណោះ ។

**ប្រការ ១៥**- ការសំរេចចិត្តរបស់ EQMC នៅក្នុងការអនុវត្តការដេញថ្លៃ ជាការសំរេចចុងក្រោយ ។

**ប្រការ ១៦**- នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករសំលៀកបំពាក់ និង សមាជិកគណកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រការនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

ចំលងជូន:
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

  " ដើម្បីជ្រាបជាពត៌មាន "
- ទូរទស្សន៍ជាតិ វិទ្យុជាតិ និងសារពត៌មានជាតិ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

**លេខ : ៣៦០ អយក.ប្រក**

# ប្រកាស

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា **បង្គលមានលក្ខណ៍**

**ឧបនាយករដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤-៨០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ
- បានឃើញព្រះរាជក្រឹត្យលេខ ជស-រកត ០៨៩៧-១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ .ប.ក ចុះថ្ងៃទី ២៣ - ៣ - ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតលេខ របស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា **បង្គលមានលក្ខណ៍** ចុះថ្ងៃទី ២៦ ខែ មេសាឆ្នាំ ២០០២ ដោយមានចំណារឯកភាព របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត តាកែវ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០២
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ១** : - ប្តូរឈ្មោះសាលាបឋមសិក្សា **បង្គលមានលក្ខណ៍** មកជាសាលាបឋមសិក្សា " **សុខ អាន បង្គលមានលក្ខណ៍** " ដែលមានទីតាំងស្ថិតនៅ ឃុំ **ត្រពាំងធំខាងជើង** ស្រុក **ត្រាំកក់** ខេត្ត **តាកែវ** ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** : - បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣** : - នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **តាកែវ** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **ត្រាំកក់** នាយកសាលាបឋមសិក្សា " **សុខ អាន បង្គលមានលក្ខណ៍** " មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ ,ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០០២

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម.សិទ្ធី**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាបជាពត៌មាន "

- សាលាខេត្ត តាកែវ " ជូនជ្រាបជាពត៌មាន "
- ដូចប្រការ ៣
- កាលប្បវត្តិ
- ឯកសារ នា -ប.ម

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ 157 [illegible]- កសក

# សារាចរ
## ស្តីពី
## វិធានការគ្រប់គ្រង និង ទប់ស្កាត់
## ភាពអនាធិបតេយ្យចលនាសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

ដើម្បីពង្រឹងការអនុវត្តន៍អនុក្រឹត្យលេខ ១៤ អនក្រ. ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៨៨ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ និង សារាចរណែនាំលេខ ០២៩ កសក.សារណន ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៨៩ ស្តីពីការអនុវត្តន៍អនុក្រឹត្យលេខ ១៤ អនក្រ. ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៨៨ និង ដោយសង្កេតឃើញថា បច្ចុប្បន្ននេះជម្ងឺសត្វបានកើតមានឡើង និង ឆ្លងរាលដាលពីតំបន់មួយទៅតំបន់មួយទៀត ក៏ដូចជាមានអំពើចោរកម្មលួចសត្វគោ-ក្របីរបស់ប្រជាកសិករកាន់តែមានសន្ទុះខ្លាំងក្លាឡើងផងនោះ ដូច្នេះដើម្បីទប់ស្កាត់ជម្ងឺសត្វ និង អំពើចោរកម្មខាងលើសំដៅបង្កើនផលិតភាពកសិកម្ម ផលិតកម្មសត្វ និង កម្លាំងអូសទាញ ដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាកសិករ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមធ្វើការណែនាំដល់នាយកដ្ឋានផលិតកម្ម បសុព្យាបាល និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទគ្រប់ខេត្ត ក្រុងដូចខាងក្រោម :

- សហការជាមួយរដ្ឋបាល ឃុំ សង្កាត់ អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ និង អង្គភាពពាក់ព័ន្ធ ដើម្បីទប់ស្កាត់ភាពអនាធិតេយ្យនៃចលនាសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ។
- ចលនាសត្វគោ-ក្របី និង ផលិតផលមានដើមកំណើតពីសត្វនៅពេលយប់ចាប់ពីម៉ោង ២០ ដល់ម៉ោង ៥ ភ្លឺ ដោយគ្មានលិខិតអនុញ្ញាតពីសមត្ថកិច្ចផលិតកម្ម និង បសុព្យាបាល ត្រូវហាមឃាត់ជាបណ្តោះអាសន្ន ។ ជនល្មើស និង វត្ថុតាងល្មើសច្បាប់ត្រូវឃាត់ទុកដើម្បីកសាងសំណុំរឿងតាមនីតិវិធី ។
- ពង្រឹងបន្ថែមលើការស្រាវជ្រាវ ត្រួតពិនិត្យនូវបរិមាណសត្វ សុខភាពសត្វ និង ធ្វើភិនសត្វ ដើម្បីរក្សា

និរន្តរភាពផលិតផលសត្វ ។

- កំណត់ទីកន្លែងប្រមូលទិញគោ-ក្របីជូនអាជីវករដែលបានទទួលគោលការណ៍នាំចេញ ឬ ប្រើប្រាស់ក្នុងស្រុក ។
- ត្រូវមានលិខិតអនុញ្ញាតពីសមត្ថកិច្ចផលិតកម្ម និង បសុព្យាបាលក្នុងការដឹកជញ្ជូនគោ-ក្របីដោយភ្ជាប់មកជាមួយនូវភិនសត្វគោ-ក្របី និង លិខិតទិញ-លក់សត្វដែលមានបញ្ជាក់ពីរដ្ឋបាលឃុំ សង្កាត់ សាមី ។
- ចលនាកសិករឱ្យយកចិត្តទុកដាក់ក្នុងការចិញ្ចឹមសត្វគោ-ក្របីជាលក្ខណៈគ្រួសារ សមូហភាព និង ជាលក្ខណៈពាក់កណ្ដាលឧស្សាហកម្ម ដើម្បីបង្កើនចំណូលរបស់គ្រួសារ និង ចលនាកសិករក្នុងសហគមន៍ឱ្យចេះសហការគ្នាថែទាំសត្វគោ-ក្របីដែលជាកម្លាំងអូសទាញដ៏សំខាន់ក្នុងការបង្កបង្កើនផលកសិកម្ម ។

ទទួលបានសារាចរនេះ នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទគ្រប់ខេត្ត ក្រុង ត្រូវអនុវត្តតាមខ្លឹមសារខាងលើឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី 22 ខែ ឧសភា ឆ្នាំ ២០០២

រដ្ឋមន្ត្រី

ចិន្ត- សារុន

កន្លែងទទួល :

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ